ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ និង ក្រសួងផែនការ**
លេខ:...២៤.០០..................ប្រ.ក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការកែសម្រួលប្រការ២៩នៃប្រកាសអន្តរក្រសួង ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

## សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងផែនការ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/៥០១/១៧៥ ចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនុក្រ.ប្រក ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញប្រកាសអន្តរក្រសួង លេខ ០៩៨ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ របស់ក្រសួងមហាផ្ទៃ និង ក្រសួងផែនការ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- យោងតាមសេចក្តីសំរេចនៃអង្គប្រជុំគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ កាលពីថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០២ ។

# សំរេច

**ប្រការតែមួយ.–**

កែសម្រួលប្រការ២៩ នៃប្រកាសអន្តរក្រសួង លេខ ០៩៨ ប្រ.ក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ដូចខាងក្រោម ។

**ប្រការ២៩ ថ្មី.–**

ចំពោះឃុំ សង្កាត់ ដែលមានគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ តាមរចនាសម្ព័ន្ធអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល សមាជិកនៃគណៈកម្មាធិការកសាងផែនការ និង ថវិកាឃុំ សង្កាត់ ដែលជាតំណាងអាជ្ញាធរភូមិ ដូចមានចែងក្នុងប្រការ៩នៃប្រកាសអន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ត្រូវយកតំណាងម្នាក់ពីអាជ្ញាធរភូមិ និង តំណាងម្នាក់ពីគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ។ តំណាងទាំងពីររូបខាងលើនេះ ត្រូវមានបុរសម្នាក់ និង នារីម្នាក់ ។

ករណីចាំបាច់គណៈកម្មាធិការកសាងផែនការ និង ថវិកាឃុំ សង្កាត់ អាចបង្កើតក្រុមការងារមួយដើម្បីជួយសម្របសម្រួលការងាររបស់ខ្លួនបាន ។ ក្រុមការងារនេះ ត្រូវជ្រើសរើសយកតែសមាជិកក្នុងគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់ តាមការសំរេចរបស់មេឃុំ ចៅសង្កាត់ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ[illegible] ឆ្នាំ ២០០២

ហត្ថលេខា និងត្រា
សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា និងត្រា
រដ្ឋមន្ត្រីក្រសួងផែនការ

***កន្លែងទទួល :***

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- សមាជិក " គ.ឃ.ស. "
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
- សាលាខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ